**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ១១២ សណ ១៦ អអក

ភ្នំពេញ, ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០១៦

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់លើលើគម្រោងកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ឈឹម សារពេទ៍ និងសេវាករ ខៀវ សុផល ដែលភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិ នៅខេត្តឧត្តរមានជ័យ

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ឈឹម សារពេទ៍ និងសេវាករ ខៀវ សុផល នៅស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ មេត្តាជ្រាបថា កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាបានបញ្ចុះថ្លៃលក់អគ្គិសនីឲ្យអ្នកកាន់-អាជ្ញាបណ្ណទាំង២តំបន់ខាងលើ មកស្មើនឹង១០៥០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ដើម្បីសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអ្នកប្រើប្រាស់ផង និងទុកលទ្ធភាពឲ្យអ្នកធ្វើសេវាកម្មអាចរក្សាបានដំណើរការផ្គត់ផ្គង់អគ្គិសនីផង ។ យោងតាមផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា និងយោងតាមយន្តការឧបត្ថម្ភធនដែលបានកំណត់សម្រាប់ឆ្នាំ២០១៦នេះ ចាប់ពីខែមីនា ឆ្នាំ២០១៦ ដែលត្រូវនឹងវិក្កយបត្រចេញនៅចុងខែមីនា ឬដើមខែមេសា ចំពោះតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណដែលយកប្រភពអគ្គិសនីរបស់បណ្តាញជាតិមកផ្គត់ផ្គង់ អាជ្ញាធរអគ្គិសនីកម្ពុជានឹងកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ក្នុងតំបន់របស់សេវាករ ឈឹម សារពេទ៍ និងសេវាករ ខៀវ សុផល ទៅតាមប្រភេទអតិថិជន លក្ខខណ្ឌ និងអត្រា ដូចក្នុងតារាងខាងក្រោម ៖

| លេខរៀង ប្រភេទ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃលក់ |
|---|---|
| ១.សម្រាប់អ្នកប្រើប្រាស់ដែលទិញអគ្គិសនីតាមនាឡិកាស្ទង់តង់ស្យុងមធ្យមពីបណ្តាញតង់ស្យុងមធ្យមរបស់ "អ្នកចែកចាយអគ្គិសនី" | 0.1675 $US/kWh |
| ២.សម្រាប់អ្នកប្រើប្រាស់ដែលទិញអគ្គិសនីតាមនាឡិកាស្ទង់ LV ក្រោមត្រង់ស្វូ MV/LV និងបានវិនិយោគដាក់ត្រង់ស្វូ នាឡិកាស្ទង់ LV និងឌីស្យុងទ័រួម LV ដោយខ្លួនឯង | 0.1745 $US/kWh |
| ៣.សម្រាប់អ្នកប្រើប្រាស់ដែលទិញអគ្គិសនីតាមនាឡិកាស្ទង់ LV ក្រោមត្រង់ស្វូ MV/LV ដែលត្រង់ស្វូ នាឡិកាស្ទង់ LV និងឌីស្យុងទ័រួមនេះ វិនិយោគដោយ "អ្នកចែកចាយអគ្គិសនី" | 0.1840 $US/kWh |
| ៤.សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទដែលទិញអគ្គិសនីតាមខ្សែបណ្តាញតង់ស្យុងទាប របស់ "អ្នកចែកចាយអគ្គិសនី" | 800 រៀល/kWh |
| ៥.សម្រាប់អ្នកប្រើប្រាស់ប្រភេទគេហដ្ឋានដែលប្រើមិនលើស ១០គីឡូវ៉ាត់ម៉ោងក្នុង១ខែ និងទិញអគ្គិសនីតាមខ្សែបណ្តាញតង់ស្យុងទាប របស់ "អ្នកចែកចាយអគ្គិសនី" | 480 រៀល/ kWh |
| ៦.សម្រាប់អ្នកបូមទឹកធ្វើកសិកម្មដែលប្រើប្រាស់ពេលយប់ពីម៉ោង ៩ យប់ ដល់ ម៉ោង ៧ ព្រឹក ដែលមាននាឡិកាស្ទង់ដោយឡែកកំណត់ដោយមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ | 480 រៀល/ kWh |



**អាជ្ញាធរអគ្គិសនីកម្ពុជា :** ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា សូមដាក់ "ឯកសារបញ្ជីថ្លៃលក់អគ្គិសនី" ថ្មីនេះ ពិគ្រោះយោបល់ជាសាធារណៈជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់អគ្គិសនីទាំងអស់ ដែលឋិតនៅក្នុងតំបន់ធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាបណ្ណទាំង២ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ។ ក្រោយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ "ឯកសារបញ្ជីថ្លៃលក់អគ្គិសនី" ថ្មីនេះនឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកធ្វើសេវាកម្មចែកចាយ ផង ។ ឯកសារគណនាបញ្ជីថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ អាជ្ញាធរអគ្គិសនីកម្ពុជា ទីតាំងធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាបណ្ណទាំង២តំបន់ សាលាស្រុក សាលាខេត្ត សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់ទាំងអស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរីនៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh